# នួន ជា គឺជាជនម្នាក់ ដែលបានសរសេរទស្សនាវដ្ដីទង់បដិវត្តន៍

**ដោយ ៖ ចាន ប្រាថ្នា**

(ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១)

នៅរសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានចោទសំណួរទៅកាន់ជនជាប់ចោទ នួន ជា ។ សហព្រះរាជអាជ្ញាបានចោទសំណួរដោយផ្ដោតសំខាន់ទៅលើតួនាទីរបស់ជនជាប់ចោទរូបនេះក្នុងការអប់រំគោលនយោបាយរបស់បក្សទៅកាន់កម្មាភិបាលថ្នាក់ក្រោម ។ សំណួរមួយក្នុងចំណោមសំណួរជាច្រើនដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក Dale Lysak បានសួរជនជាប់ចោទ នួន ជា គឺថា *តើជនជាប់ចោទរូបនេះធ្លាប់បានទទួលទស្សនាវដ្ដីទង់បដិវត្តន៍ដែរឬទេ?* ឆ្លើយតបទៅនឹងសំណួរនេះ ជនជាប់ចោទ នួន ជា បានឆ្លើយថា *«ខ្ញុំបានទទួលដែរ ព្រោះអ្នកធ្វើទង់បដិវត្តន៍គឺជាគណៈអចិន្ត្រៃយ៍* ***ពិសេសអ្នកសរសេរគឺជាលេខាបក្សហើយនិងខ្ញុំ****»* ។ មានន័យថាមិនត្រឹមតែជនជាប់ចោទ នួន ជា បានទទួលទស្សនាវដ្ដីទង់បដិវត្តន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខ្លួនបានសរសេរទស្សនាវដ្ដីនេះទៀតផង ។ ជនជាប់ចោទរូបនេះបានបន្ថែមទៀតថា ទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានបោះពុម្ពផ្សាយដើម្បីចែកជូន និងអប់រំដល់បក្ខជនផងដែរ ។ ផ្អែកលើទស្សនាវដ្ដីទង់បដិវត្តន៍ និងឯកសារមួយចំនួនទៀតដូចជា ឯកសារលោកទស្សនៈ សង្គមទស្សនៈ ឯកសារស្ដីពីការបែងវណ្ណៈក្នុងសង្គម... ជនជាប់ចោទ នួន ជា បានធ្វើការអប់រំនយោបាយដល់កម្មាភិបាលរបស់បក្សតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ ។

**កំណត់សម្គាល់**៖ ចម្លើយដែលជនជាប់ចោទ នួន ជា បានផ្ដល់ទាំងនេះគឺមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងកថាខណ្ឌមួយចំនួន ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ (ដីកានេះត្រូវបានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្សព្វផ្សាយក្នុងគេហទំព័ររបស់ខ្លួនជាសាធារណៈ) ។ ជាក់ស្ដែងកថាខណ្ឌទី៩៩ នៃដីកានេះបានកំណត់ថា «ទស្សនាវដ្ដីទង់បដិវត្តន៍ និងទស្សនាវដ្ដីយុវជនយុវនារីបដិវត្តន៍ គឺជាទស្សនាវដ្ដីដែលមានសារៈសំខាន់បំផុតរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការផ្សព្វផ្សាយ ហើយបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មេដឹកនាំជាន់ខ្ពស់របស់បក្ស ជាពិសេសទស្សនៈរបស់គណៈអចិន្ត្រៃយ៍...» ។ កថាខណ្ឌទី១០១ នៃដីកានេះបានកំណត់ផងដែរថា «ទស្សនាវដ្ដីទង់បដិវត្តន៍ និងទស្សនាវដ្ដីយុវជនយុវនារីបដិវត្តន៍ គឺជាឧបករណ៍ឃោសនាមួយដែលត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងអំពីនយោបាយរបស់បក្ស..ហើយទស្សនាវដ្ដីទាំងនោះត្រូវបានផ្សព្វផ្សាយដើម្បីបង្រៀនដល់កម្មាភិបាលទាំងផ្នែកនយោបាយ និង យោធា ។...» ។

តើទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានយកមកប្រើដើម្បីអ្វី នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា?

យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទ នួន ជា និង កថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការអប់រំនយោបាយ ទស្សនាវដ្ដីទង់បដិវត្តន៍មានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយពីគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាទៅដល់កម្មាភិបាលថ្នាក់ក្រោមៗ ។ កថាខណ្ឌ១០២នៃដីកាដំណោះស្រាយបានបន្ថែមថា "...ខ្លឹមសារនៃការផ្សព្វផ្សាយតាមវិទ្យុត្រូវបានដកស្រង់ចេញពីអត្ថបទនានាដែលមាននៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍នេះ ។ ឯកសារទស្សនាវដ្ដីទង់បដិវត្តន៍ជាច្រើនច្បាប់ត្រូវបានប្រទះឃើញផងដែរនៅក្នុងមន្ទីរស-២១និងនៅផ្ទះជុំវិញបរិវេណនោះ ។ ឌុច ខ្លួនឯងក៏បានបញ្ជាក់ថា គាត់បានប្រើប្រាស់ទស្សនាវដ្ដីទង់បដិវត្តន៍សម្រាប់ជាព័ត៌មានស្ដីពីមាគ៌ានយោបាយទូទៅរបស់បក្ស" ។ កថាខណ្ឌ១០៣នៃដីកាដដែលនេះបានកំណត់ផងដែរថា "ទស្សនាវដ្ដីទាំងនេះក៏ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការបង្រៀន ជាពិសេសបង្រៀនដោយ នួន ជា និង អៀង សារី ។ វគ្គសិក្សារៀនសូត្រទូទៅជាច្រើនត្រូវបានធ្វើឡើងដើម្បីប្រមូលផ្ដុំ និងអប់រំ ឲ្យយុវជន និងយុវនារី ដើម្បីចូលរួមបដិវត្តន៍ ។ យោងតាមសាក្សីមួយចំនួនបានលើកឡើងថា គោលការណ៍ណែនាំនៅក្នុងទស្សនាវដ្ដីត្រូវបានបង្ហាញពីរបៀបធ្វើការដ៏ម៉ត់ចត់ ហើយប្រសិនបើមនុស្សណាម្នាក់មិនសម្របខ្លួនតាមខ្លឹមសារទស្សនាវដ្ដីនេះទេ អ្នកនោះនឹងត្រូវចាត់ទុកថាជាខ្មាំងដោយស្វ័យប្រវត្តិ..." ។

ចប់